ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ
## កិច្ចប្រជុំ ជុំនួបពិភាក្សាជាមួយប្រតិភូសាធារណរដ្ឋឥណ្ឌូនេស៊ី និងចែករំលែក បទពិសោធន៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

ថ្ងៃអង្គារ ០៩រោចខែ ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹង ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២៥។ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បាន រៀបចំកិច្ចប្រជុំ ជុំនួបពិភាក្សាជាមួយប្រតិភូសាធារណរដ្ឋឥណ្ឌូនេស៊ី និងចែករំលែកបទពិសោធន៍ការងារប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៅសាលប្រជុំខេត្តបាត់ដំបង ក្រសួងមហាផ្ទៃ។

**ក. សមាសភាពចូលរួមមាន៖**

១-ភាគីខាងកម្ពុជា៖

-លោកជំទាវអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

-លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-និងឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង លោកទីប្រឹក្សា លោកប្រធាន អនុប្រធានលេខាធិការដ្ឋាន រដ្ឋបាលសរុប លោកស្រី លោកស្រី ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ នាយ នាយរង ការិយាល័យ និងមន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៣៧នាក់ ស្រី ០៦រូប

២-ភាគីខាងឥណ្ឌូនេស៊ី៖

-ឧត្តមសេនីយ៍ទោ ស្លាម៉ិត ហាឌី ស៊ូប្រាប់តូយ៉ូ (SlametHadi Supraptoyo, S.H., M.H.)

-តំណាងប្រធានការិយាល័យ វិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់នគរបាលជាតិ ឥណ្ឌូនេស៊ី

-ឧត្តមសេនីយ៍ទោ មូសា អ៊ីគីពសុន ម៉ាណាអែក តាំពូបូឡុន (Musa Ikipson Manaek Tampubolon S.H. M.Si)

-ឧត្តមសេនីយ៍ត្រី ឌិកគី ប៉ាទ្រីយ៉ា នើហ្គារ៉ា (Dicky Patria Negara, S.H. S.I.K., M.Si.)

-ឧត្តមសេនីយ៍ត្រីស្លាម៉ិត ហារីយ៉ាឌី (Slamet Hariyadi M.H.,M.M.)

-វរសេនីយ៍ឯក អ៊ិកណាទីយុស វីណារតូ(Ignatius Winarto S.I.K. M.H.)

-វរសេនីយ៍ឯក Wino Sumarno, S.S. M.Pd.

-វរសេនីយ៍ទោ អារដ្យាន់តូ បាយូ វីបូវ៉ូ (ArdiantoBayu Wibowo S.H., KOM, SH.,M.M.,M.Si)

-អនុសេនីយ៍ត្រីរីហ្សាល់ រ៉ាម៉ាដាន់ (Rizal Ramadhan)

-អនុសេនីយ៍ត្រី រីហ្វគី មូហ្សាគី អាហ្សស្វាត(RifkiMuzaki Azwat)

-និងមានមន្ត្រីគណៈប្រតិភូឥណ្ឌូនេស៊ីជាច្រើនរូបទៀត ក្នុងនោះក៏មាន មន្ត្រីយោធា មន្ត្រី បង្ក្រាបបទល្មើស បច្ចេកវិទ្យា មន្ត្រីតុលាការ និងមន្ត្រីអគ្គស្នងការនគរបាលផងដែរ ដែលមកធ្វើកម្មសិក្សាពាក់ព័ន្ធនឹងការងារ ប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស មានចំនួន ៤១នាក់ ស្រី ០១នាក់ ។

សរុបសមាសភាពចូលរួមមានចំនួន ៧៨នាក់ ស្រី ០៧នាក់

## ខ-គោលបំណង

គោលបំណង នៃទស្សនកិច្ចរបស់ប្រតិភូសាធារណរដ្ឋឥណ្ឌូនេស៊ី គឺចង់ដឹងនូវព័ត៌មាន នៃការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដែលមានដូចជា ការដោះស្រាយបញ្ហា ការបញ្ជូន និងការទទួល ពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស និងឧក្រិដ្ឋកម្មផ្សេងៗ ដែលអនុវត្តទៅតាមទិដ្ឋភាពច្បាប់ ឬការអនុត្តតាមច្បាប់នៃប្រទេសកម្ពុជា។

## គ. លទ្ធផលនៃកិច្ចប្រជុំ

❖ លោកជំទាង ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ក៏បានបង្ហាញនូវការស្វាគមន៍ ចំពោះសំណើរបស់ភាគីឥណ្ឌូនេស៊ី ដល់ចង់ដឹងពីបទពិសោធន៍ នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមជាមួយនឹងការប្ដេជ្ញា បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរឥណ្ឌូនេស៊ី លើការងារបង្ការទប់ស្កាត់អំពើឆ្លងដែនខុសច្បាប់ ឧក្រិដ្ឋកម្មឆ្លងដែន និងបទល្មើសជាច្រើនទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ក៏ដូចជាក្នុងតំបន់ និងពិភពលោកទាំងមូល។

លោកជំទាង **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថា ក្នុងនាមនាងខ្ញុំតំណាងឱ្យឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសោមនស្សរីករាយ ដែលបានទទួលគណៈប្រតិភូនៃសាធារណរដ្ឋឥណ្ឌូនេស៊ីមកធ្វើទស្សនកិច្ចសិក្សាស្វែងយល់នៅកម្ពុជា។ លោកជំទាវក៏បានលើកឡើង និងគិតថា អារម្មណ៍របស់ ឯកឧត្តម លោក លោកស្រី មុនពេលមកដល់ព្រះរាជាណាចក្រកម្ពុជា ប្រហែលជាយល់ថា ប្រទេសកម្ពុជា ជាកន្លែងគួរឱ្យភ័យខ្លាច ជាប្រទេសមិនមានសុវត្ថិភាព ប៉ុន្តែមកដល់ពេលនេះ លោកជំទាវជឿជាក់ថា អារម្មណ៍របស់លោក លោកស្រី មានការផ្លាស់ប្ដូរ ពីព្រោះការរស់នៅទីនេះជីវិតរបស់យើងទាំងអស់គ្នា គឺធម្មតា មិនមានការភ័យខ្លាច យើងអាចធ្វើដំណើរទាំងយប់ទាំងថ្ងៃ ដែលអាចទៅដល់ទីណាក៏បាន មានន័យថា មិនមានការភ័យខ្លាច មានជនបង្កបទល្មើសនោះទេ លោកជំទាវក៏បានយល់ថាពិតជាសប្បាយរីករាយថា តើគណៈប្រតិភូយល់ពីកម្ពុជាយ៉ាងដូចម្ដេច លោកជំទាវក៏មិនបានបដិសេធចំពោះប្រទេសកម្ពុជាមិនមានបទល្មើសនោះទេ ហើយក៏សុំបដិសេធមិនមែនជាកន្លែងប្រព្រឹត្តបទល្មើសដែរ ប៉ុន្តែយើងក៏បានខិតខំប្រឹងប្រែងជានាដើម្បីឱ្យប្រជាជនកម្ពុជា និងជនបរទេសដែលរស់នៅ ក្នុងប្រទេសកម្ពុជា មានសេចក្តីសុខ សុវត្ថិភាព ដើម្បីការរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ និងមានការគោរពសិទ្ធិមនុស្ស ក៏ដូចជាការប្រកបមុខរបរ និងធ្វើការងារប្រកបដោយសុវត្ថិភាព។ លោកជំទាវក៏បាន សម្ដែងការរីករាយកោតសរសើររាជរដ្ឋាភិបាលឥណ្ឌូនេស៊ី ដែលបានបញ្ជូនកម្មសិក្សាការីឱ្យមកធ្វើ ទស្សកិច្ច សិក្សាស្វែងយល់ពីកម្ពុជា ក៏ដូចជានៅតាមបណ្ដាប្រទេសនានា នេះគឺជាមធ្យោបាយតែមួយគត់ដែលយើងអាចមើលឃើញការពិតនៅក្នុងតំបន់របស់យើង ហើយក៏បានដកបទពិសោធន៍ ធ្វើសកម្មភាពការងារនៅក្នុងប្រទេសរបស់យើងផងដែរ។ ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីបានជ្រាបហើយ មិនមានតែឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងប្រទេសកម្ពុជាមួយទេ គឺពួកគេមានបណ្ដាញប្រទាក់ក្រឡាគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាក៏មានការព្រួយបារម្ភ និងយល់ថាប្រហែលជាមានបទលើសនេះ មាននៅតែកម្ពុជាទេ ប៉ុន្តែអ្វីដែលយើងបានឃើញ មានជនជាតិបរទេសជាច្រើនសញ្ជាតិ បានចូលមកដល់កម្ពុជា ក្នុងនាមជាជនរងគ្រោះផង ជាជនល្មើសផង និង ក្នុងនាមជាអ្នកប្រកបមុខរបរធ្វើអាជីវកម្មផង ដូច្នេះមានន័យថាបណ្ដាញទំនាក់ទំនងរបស់ឧក្រិដ្ឋជន គឺមាននៅគ្រប់ទីកន្លែង រហូតដល់គេអាចទាក់ទាញឲ្យជនបរទេសទាំងឡាយចូលមកកម្ពុជាបានយ៉ាងងាយ តែកម្ពុជាខ្លួនឯងក៏មិនមានលទ្ធភាពប្រមូលឲ្យជនបរទេសចូលមកកម្ពុជាបានទេ

ដូច្នេះប្រទេសនីមួយៗ ចាំបាច់ណាស់ត្រូវតែធ្វើការសិក្សាស្វែងយល់ថា តើឧក្រិដ្ឋជនមានបង្កប់ខ្លួនធ្វើជាជនធម្មតា ដែលធ្វើឲ្យយើងមានការពិបាកនឹងកំណត់មុខសញ្ញាបាន។ ហេតុនេះការបង្ក្រាបរបស់យើងបច្ចុប្បន្ន បានខិតខំប្រឹងប្រែងណាស់ ប៉ុន្តែអ្វីដែលយើងអាចធ្វើបាន មានលទ្ធភាពតែក្នុងប្រទេសខ្លួនឯងប៉ុណ្ណោះ ហើយយើងពុំមានលទ្ធភាពអាចធ្វើការបន្តស្រាវជ្រាវទៅ ក្រៅប្រទេសបានដែលដូច្នេះយើងត្រូវតែបន្តសហការគ្នាជាចាំបាច់ណាស់ទើបយើងអាចលប់បំបាត់នូវបទល្មើសទាំងនោះប្រកបដោយប្រសិទ្ធភាព។

បន្ទាប់មក លោកជំទាវបានថ្លែងអំណរគុណដល់គណៈប្រតិភូ ទាំងអស់ និងនៅរង់ចាំស្វាគមន៍ សំណួរចម្លើយ ពីឯក.ឧត្តម លោក លោកស្រី នៃគណៈប្រតិភូឥណ្ឌូនេស៊ី ហើយជាមួយគ្នានេះ លោក ជំទាវក៏ចង់ស្នើសុំការសិក្សាស្វែងយល់ពីគណៈប្រតិភូឥណ្ឌូនេស៊ីផងដែរ ដែលប្រទេសឥណ្ឌូនេស៊ីមានបទពិសោធន៍ច្រើន លើការងារធ្វើការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ទទួលបានជោគជ័យសម្រាប់ប្រទេសឥណ្ឌូនេស៊ី។

❖ **តំណាងគណៈប្រតិភូនៃវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ឥណ្ឌូនេស៊ី** បានលើកឡើងថា ក្នុងឱកាសធ្វើដំណើរកម្មសិក្សា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា ឯកឧត្តមគណៈប្រតិភូក៏បានជម្រាបជូននូវសមាសភាពរបស់ខ្លួន មានចំនួនសរុប ៤១នាក់ ក្នុងនោះមានក្រុមការងារដូចជា មន្ត្រីនគរបាលបង្ក្រាបបទល្មើស មន្ត្រីផ្នែកយុត្តិធម៌ រួមទាំងមន្ត្រីជំនាញផ្សេងៗ ជាច្រើនរូបទៀត ហើយមន្ត្រីទាំងនោះ សុទ្ធតែមកពីបណ្តាខេត្តខុសៗគ្នា គឺដើម្បីជួយសម្រួលក្នុងការងារនេះ។ ខណៈនោះដែរពួកគាត់បានអះអាងថា សន្តិសុខនៅក្នុងប្រទេសកម្ពុជា មានភាពល្អប្រសើរ គឺខុសពីអ្វីដែលធ្លាប់បានលឺ ពីការផ្សព្វផ្សាយនូវព័ត៌មានមួយចំនួន ដែលធ្លាប់បន្ទុចបង្អាប់កម្ពុជាកន្លងមក ចំពោះក្តីសុខ និងសុវត្ថិភាព គឺជារឿងចម្បងមួយដែលសំខាន់ ហើយចំពោះសុខសុវត្ថិភាព នៅក្នុងប្រទេសកម្ពុជា គឺខុសពីអ្វីដែលគណៈប្រតិភូឥណ្ឌូនេស៊ីបានគិតពីមុន ព្រោះពេលមកដល់កម្ពុជា ឃើញថាសន្តិសុខមានភាពល្អប្រសើរ គឺគ្មានអ្វីមករំខានយើងទេ ហើយនៅពេលត្រឡប់ទៅប្រទេសឥណ្ឌូនេស៊ីវិញ នឹងផ្សព្វផ្សាយពីដំណឹងនេះ ទៅកាន់ប្រជាពលរដ្ឋឥណ្ឌូនេស៊ី ខណៈគណៈប្រតិភូបានចាត់ទុកថា កម្ពុជាដូចជាផ្ទះរបស់ខ្លួនផងដែរ។ ខណៈនោះដែរគណៈប្រតិភូ ក៏បានជម្រាបលោកជំទាវថា ពួកគាត់ មកទីនេះ គឺចង់សិក្សាស្វែងយល់ពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានបទពិសោធន៍ទាំងខាងការងារបង្ក្រាប ទាំងខាងអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយពួកគាត់ក៏ចង់ដឹងផងដែរថាតើ គ.ជ.ប.ជ មាននីតិវិធីបែបណាក្នុងការអនុវត្តច្បាប់ និងការបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់ចំពោះជនបរទេស និងសំណួរមួយទៀត ថាតើ គ.ជ.ប.ជ មានទម្រង់រចនាសម្ព័ន្ធយ៉ាងដូចម្តេច? ជាចុងក្រោយតំណាងគណៈប្រតិភូ បានថ្លែងអំណរគុណដល់លោកជំទាវអនុប្រធាន អចិន្ត្រៃយ៍ និងថ្នាក់ដឹកនាំការងារអនុវត្តច្បាប់ ហើយពួកគាត់នឹងសង្ឃឹមថា និងបន្តកិច្ចសហប្រតិបត្តិការឱ្យបានល្អរវាងប្រទេសរបស់យើងទាំងពីរ។

❖ បន្ទាប់មកទៀត **លោកជំទាវ** ក៏បានធ្វើបទបង្ហាញនូវស្លាយជារូបភាព ដែលជាលទ្ធផល និងជាបទពិសោធន៍សម្រេចបាន ក្នុងការអនុវត្តច្បាប់ និងបង្ក្រាប បទល្មើស របស់ជនបរទេស ដែលបានធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជាជូនគណៈប្រតិភូឥណ្ឌូនេស៊ី ដើម្បីឲ្យពួកបានស្វែងយល់ ពីកម្ពុជាដែលរាជរដ្ឋាភិបាល កម្ពុជាយើងកំពុងអនុវត្តការងារនេះយ៉ាងសកម្ម។ ក្នុងនោះផងដែលលោកជំទាវ ក៏បានលើកផងដែល អំពីពលរដ្ឋកម្ពុជាដែលបានលួចចូលឆ្លងដែលខុសច្បាប់ទៅធ្វើការ នៅប្រទេសថៃ ជាពិសេសនៅក្នុងអំឡុងឆ្នាំ ២០១៤-២០១៩ ដែលចេញទៅពុំមានឯកសារត្រឹមត្រូវ ដែលពួកគេភាគច្រើនទៅតាមមេខ្យល់ និងចាញ់បោកមេខ្យល់ ដោយបានលួចចេញទៅតាមច្រករបៀង ដែលពុំមានសុវត្ថិភាព ធ្វើឲ្យពួកយើងពិបាកនឹងគ្រប់គ្រងពួកគាត់ និងជាហេតុធ្វើឲ្យអាជ្ញាធរប្រទេសថៃ ចាប់ពួកគាត់បញ្ជូនមកវិញជាច្រើន ដោយភាគីថៃមិនបានជូនដំណឹងមកកម្ពុជាឡើយ នៅក្នុងអំឡុង

ពេលនោះដែរក៏មានការផ្ទុះខ្លាំងនូវជំងឺកូវីដ-១៩ ជាហេតុធ្វើឱ្យអម្រែករបស់រាជរដ្ឋាភិបាលទទួលបន្ទុកកើនឡើងទ្វេដង ទាំងការរក្សាសន្តិសុខ សុវត្ថិភាព ដោយមានការពិនិត្យថែទាំសុខភាពជូនប្រជាជនទូទាំងប្រទេស និងមានការទទួលខុសត្រូវគ្រប់បែបយ៉ាងចំពោះពលករខុសច្បាប់ដែលអាជ្ញាធរថៃបានបញ្ជូនមកកម្ពុជាវិញ រាជរដ្ឋាភិបាលបានដាក់ចេញគោលការណ៍សំខាន់ៗ ដែលមានតួនាទី និងភារកិច្ចក្នុងការជួយដោះស្រាយនូវបញ្ហាលំបាកសព្វបែបយ៉ាងដើម្បីប្រជាជនរបស់ខ្លួន។

លោកជំទាវ ក៏បានមានប្រសាសន៍ជម្រាបជូនគណៈប្រតិភូឥណ្ឌូនេស៊ី អំពីរចនាសម្ព័នរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ ដែលបានបង្កើតឡើងនៅឆ្នាំ២០១៤ ហើយ គ.ជ.ប.ជ មានប្រធាន គ.ជ.ប.ជ ដឹកនាំដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គ.ជ.ប.ជ មានតួនាទី និងភារកិច្ច ជាអ្នកធ្វើការសម្របសម្រួល ទំនាក់ទំនងក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ក្នុងការអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងមានរចនាសម្ព័ន្ធចាប់ពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ ចំពោះថ្នាក់ជាតិមាន ប្រធានក្រុមការងារទាំង៦ របស់អន្តរក្រសួង ដែលមានតួនាទីជាអនុប្រធាន គ.ជ.ប.ជ ដូចមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងយុត្តិធម៌, ក្រសួងសង្គមកិច្ច យុវនីតិសម្បទា, ក្រសួងកិច្ចការនារី, ក្រសួងអប់រំយុវជន និងកីឡា និងអគ្គស្នងការដ្ឋាននគរបាលជាតិ។ រីឯថ្នាក់ក្រោមជាតិ មានប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.រ.ប.ជ/គ.ខ.ប.ជ) និងប្រធានលេខាធិការដ្ឋាន (គ.រ.ប.ជ/គ.ខ.ប.ជ) ទាំង២៥ រាជធានី-ខេត្ត។

❖ ចំណែកឯភាគីគណៈប្រតិភូឥណ្ឌូនេស៊ី ក៏បានជម្រាបជូនថា ខាងពួកគាត់ក៏មានរចនាសម្ព័ន្ធប្រហាក់ប្រហែលនឹងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដុរមនុស្សយើងដែរ។

មុននឹងបញ្ចប់កិច្ចប្រជុំពិភាក្សា គណៈប្រតិភូឥណ្ឌូនេស៊ី ក៏បានធ្វើការជូនវត្ថុអនុស្សាវរីយ៍ដល់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចំណែកឯ គ.ជ.ប.ជ យើងបានជូនក្រមាដល់គណៈប្រតិភូឥណ្ឌូនេស៊ីម្នាក់មួយៗ ទុកជាអនុសហសាវរីយ៍ផងដែរ។

កិច្ចប្រជុំ បានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំពី និងសសិបនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងភាពស្និទ្ធស្នាល។

ថ្ងៃច័ន្ទ ១៤រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥

*បានឃើញ និងសូមគោរពជូន*
***លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាប ដ៏ខ្ពង់ខ្ពស់***
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណា សំខាន់

**អ្នកធ្វើរបាយការណ៍**

វរៈសេនីយ៍ឯក. អ៊ុន-សុខជា

30/05/25

ឌូ-ប៊ុនរអេង